# ថ្នាំបង្ការជំងឺឆ្កែឆ្កួត
## *អ្វីដែលអ្នកត្រូវការដឹង*

របាយការណ៍ព័ត៌មានស្តីអំពីថ្នាំបង្ការជាច្រើនមានជាភា សាអេស្ប៉ាញនិងភាសាដទៃទៀត។ សូមមើលនៅ ក្នុងគេហទំព័រ www.immunize.org/vis

## 1 ជំងឺឆ្កែឆ្កួតគឺជាអ្វី?

ជំងឺឆ្កែឆ្កួតភាគច្រើនជាជំងឺរបស់សត្វ។
មនុស្សកើតជំងឺឆ្កែឆ្កួតនៅពេលពួកគេត្រូវបានខាំដោយសត្វមានផ្ទុកមេរោគ។
ជាបឋម អាចនឹងមិនមានរោគសញ្ញាអ្វីនោះឡើយ។
ប៉ុន្តែជាច្រើនសប្តាហ៍ឬដល់ថ្នាក់ច្រើនខែបន្ទាប់ពី ការខាំមក, ជំងឺឆ្កែឆ្កួតអាចបណ្តាលឲ្យមានការឈឺចាប់ អស់កំលាំង ឈឺក្បាល គ្រុនក្តៅនិងភាពមួម៉ៅឆាប់ច្រឡោត។
រោគសញ្ញាទាំងនេះតាមមកដោយការប្រកាច់ ភាពមមើមមាយ និងភាពខ្វិនកំរើកលែងបាន។ ជំងឺឆ្កែឆ្កួតនៅលើមនុស្សជានិច្ចកាលគឺស៊ើងតែបង្កគ្រោះថ្នាក់ដល់ស្លាប់។
សត្វព្រៃ - ជាពិសេសប្រចៀវ - គឺជាប្រភពឃើញមានច្រើនញឹកញាប់បំផុតនៃការបង្ករោគជំងឺឆ្កែឆ្កួតរបស់មនុស្សនៅក្នុងសហរដ្ឋអាមេរិក។





សត្វស្កុង សំពោចអាមេរិក ឆ្កែ ឆ្មា ចចកអាមេរិកខាងជើង កញ្ជ្រោង និងថនិកសត្វដទៃទៀតក៏អាចចំលងជំងឺនេះបានដែរ។

ជំងឺឆ្កែឆ្កួតមនុស្សគឺកំរឃើញមាននៅក្នុងសហរដ្ឋអាមេរិក។ មានត្រឹមតែ 55 ករណីដែលត្រូវ បានធ្វើរោគវិនិច្ឆ័យប៉ុណ្ណោះចាប់តាំងពីឆ្នាំ 1990 មក។ យ៉ាងនេះក្តី មនុស្សចន្លោះពី 16 000 នាក់ដល់ 39 000 នាក់ត្រូវបានផ្តល់ថ្នាំបង្ការជារៀងរាល់ឆ្នាំជាបំរុងប្រយ័ត្នបន្ទាប់ពីសត្វខាំ។ ដូចគ្នានេះដែរ ជំងឺឆ្កែឆ្កួតគឺឃើញមានញឹកញាប់ឆ្ងាយខ្លាំងណាស់នៅផ្នែកដទៃទៀតនៃពិភពលោក ដោយមានមរណភាពពាក់ព័ន្ធនឹងជំងឺឆ្កែឆ្កួតប្រហែល 40 000-70 000 ករណីនៅទូទាំងពិភពលោកជារៀងរាល់ ឆ្នាំ។
ការខាំមកពីសត្វឆ្កែដែលមិនបានទទួលថ្នាំបង្ការបង្កឲ្យមាននូវករណីស្លាប់មួយភាគធំស្មើទាំងអស់នៃករណីស្លាប់ទាំងនេះ។
**ថ្នាំបង្ការជំងឺឆ្កែឆ្កួតអាចបង្ការជំងឺឆ្កែឆ្កួតបាន។**

## 2 ថ្នាំបង្ការជំងឺឆ្កែឆ្កួត

ថ្នាំបង្ការជំងឺឆ្កែឆ្កួតត្រូវបានផ្តល់អោយអ្នកដែលស្ថិតនៅប្រឈមនឹងហានិភ័យខ្ពស់នៃជំងឺឆ្កែឆ្កួតដើម្បី ការពារពួកគេប្រសិនបើពួកគេរងប៉ះពាល់នឹងវា។
វាក៏អាចបង្ការជំងឺផងដែរប្រសិនបើវាត្រូវបានផ្តល់ឲ្យដល់មនុស្សបន្ទាប់ពីពួកគេត្រូវបានរងប៉ះពាល់នឹងវា។ ថ្នាំបង្ការជំងឺឆ្កែឆ្កួតត្រូវបានផលិតឡើងពីវីរុសជំងឺឆ្កែឆ្កួតដែលបានសំលាប់ឲ្យងាប់ហើយ។ វាមិនអាចបង្កជាជំងឺឆ្កែឆ្កួតបានឡើយ។

## 3 តើនរណាគេខ្លះគួរទទួលថ្នាំបង្ការជំងឺឆ្កែឆ្កួតហើយនៅពេលណា?

**ការផ្តល់ថ្នាំបង្ការបង្ការជាមុន (គ្មានការរងប៉ះពាល់នឹងវីរុសឆ្កែឆ្កួត)**

- អ្នកដែលប្រឈមហានិភ័យខ្ពស់នឹងការរងប៉ះពាល់ជាមួយនឹងជំងឺឆ្កែឆ្កួត ដូចជាពេទ្យសត្វ អ្នកចាប់កាន់ដឹកជញ្ជូនសត្វ បុគ្គលិកបំរើការនៅមន្ទីរពិសោធន៍ពាក់ព័ន្ធនឹងជំងឺឆ្កែឆ្កួត អ្នកដើរលុកលុយរូងភ្នំ និងបុគ្គលិកបំរើការនៅក្នុងផលិតកម្មផលិតផលជីវសាស្ត្រវីរុសឆ្កែឆ្កួត គួរតែត្រូវបានផ្តល់ជូននូវថ្នាំបង្ការជំងឺឆ្កែឆ្កួត។
- ថ្នាំបង្ការនេះក៏គួរត្រូវបានពិចារណាផងដែរសំរាប់៖
  - អ្នកដែលសកម្មភាពរបស់ខ្លួននាំពួកគេឲ្យមានការប៉ះពាល់ញឹកញាប់ ជាមួយនឹងវីរុសជំងឺឆ្កែឆ្កួតឬជាមួយនឹងសត្វដែលអាចនឹងឆ្កួត។
  - អ្នកដំណើរអន្តរជាតិដែលទំនងនឹងប៉ះពាល់ជាមួយសត្វនៅក្នុងផ្នែកនៃពិភពលោក ដែលជំងឺឆ្កែឆ្កួតឃើញកើតមានជាញឹកញាប់។

កាលវិភាគផ្តល់ថ្នាំបង្ការមុនរងការប៉ះពាល់សំរាប់ការផ្តល់ថ្នាំបង្ការជំងឺឆ្កែឆ្កួតគឺ **3 កំរិតថ្នាំបង្ការ** ផ្តល់ឲ្យ នៅពេលដូចខាងតទៅនេះ៖

កំរិតទី 1៖ នៅពេលដែលសមគួរ
កំរិតទី 2៖ 7 ថ្ងៃបន្ទាប់ពីកំរិតទី 1
កំរិតទី 3៖ 21 ថ្ងៃឬ 28 ថ្ងៃបន្ទាប់ពីកំរិតទី 1

សំរាប់បុគ្គលិកបំរើការនៅមន្ទីរពិសោធន៍និងអ្នកដទៃទៀតដែលអាចនឹងត្រូវរងប៉ះពាល់ជួនៗគ្នានឹងវីរុស ជំងឺឆ្កែឆ្កួត ការវិភាគពិសោធន៍យូរៗម្តងរកមើលភាពស៊ាំត្រូវបានគេណែនាំឲ្យជាអនុសាសន៍ ហើយកំរិតថ្នាំបង្ការសំរាប់រំលឹកគួរត្រូវបានផ្តល់ជូនតាមដែលត្រូវការចាំបាច់។ (ការធ្វើវិភាគរកកំរិតភាពស៊ាំ ឬកំរិតថ្នាំបង្ការសំរាប់រំលឹកមិនត្រូវបានណែនាំជាអនុសាសន៍សំរាប់អ្នកដំណើរឡើយ)។ សូមសាកសួរ វេជ្ជបណ្ឌិតអ្នកដើម្បីបានសេចក្តីលំអិត។

**ការផ្តល់ថ្នាំបង្ការបន្ទាប់ពីត្រូវរងប៉ះពាល់នឹងមេរោគ**

គ្រប់គ្នាដែលត្រូវសត្វខាំ ឬមិនដូចនោះដែលអាចនឹងត្រូវរងប៉ះពាល់ទៅនឹងវីរុសឆ្កែឆ្កួត គួរតែសំអាតរបួសហើយជួបវេជ្ជបណ្ឌិតជាបន្ទាន់។ វេជ្ជបណ្ឌិតនឹងធ្វើការកំនត់ថាតើពួកគេត្រូវតែទទួលថ្នាំបង្ការឬ អត់។
អ្នកដែលត្រូវរងប៉ះពាល់នឹងវីរុសហើយមិនដែលទទួលថ្នាំបង្ការការពារជំងឺឆ្កែឆ្កួតគួរតែទទួល **4 កំរិត**នៃ ថ្នាំបង្ការជំងឺឆ្កែឆ្កួត - មួយកំរិតភ្លាមៗ ហើយកំរិតបន្ថែមទៀតនៅថ្ងៃទី 3 ទី 7 និងទី 14។ពួកគេគួរតែទទួលការចាក់ថ្នាំមួយផ្សេងទៀតដែលមានឈ្មោះថា ប្រូតេអ៊ីនអង្គបដិបក្ខប្រាណសំរាប់ប្រឆាំងវីរុសឆ្កែឆ្កួតនៅពេលព្រមជាមួយគ្នានឹងកំរិតថ្នាំបង្ការលើកទីមួយ។
អ្នកដែលត្រូវបានផ្តល់ថ្នាំបង្ការពីមុនមកហើយគួរទទួលថ្នាំបង្ការជំងឺឆ្កែឆ្កួតចំនួន **2 កំរិត** - មួយកំរិតនៅពេលភ្លាមៗហើយមួយកំរិតផ្សេងទៀតនៅថ្ងៃទី 3។ ប្រូតេអ៊ីនអង្គបដិបក្ខប្រាណប្រឆាំងវីរុសឆ្កែឆ្កួតគឺ មិនត្រូវការឡើយ។



U.S. Department of Health and Human Services
Centers for Disease Control and Prevention

## 4 ប្រាប់វេជ្ជបណ្ឌិតអ្នកប្រសិនបើ.........

ពិភាក្សាជាមួយវេជ្ជបណ្ឌិតអ្នកមុនពេលទទួលថ្នាំបង្ការជំងឺឆ្កែឆ្កួតប្រសិនបើអ្នក៖

1- ធ្លាប់មានប្រតិកម្មអាលែកហ្ស៊ីធ្ងន់ធ្ងរ (គំរាមកំហែងជីវិត) ទៅនឹងកំរិតថ្នាំបង្ការពីពេលមុននៃថ្នាំ បង្ការជំងឺឆ្កែឆ្កួត, ឬទៅនឹងសមាសធាតុផ្សំណាមួយនៃថ្នាំបង្ការ; ប្រាប់វេជ្ជបណ្ឌិតអ្នកប្រសិនបើ អ្នកមានប្រតិកម្មអាលែកហ្ស៊ីធ្ងន់ធ្ងរណាមួយ

2- មានប្រព័ន្ធភាពស៊ាំខ្សោយដោយសារតែ៖
- វីរុសឬជំងឺអេដស៍ឬជំងឺមួយផ្សេងទៀតដែលប៉ះពាល់ដល់ប្រព័ន្ធភាពស៊ាំ
- ការព្យាបាលជាមួយឱសថដែលជះឥទ្ធិពលលើប្រព័ន្ធភាពស៊ាំ ដូចជាឱសថក្រុម Steroid
- ជំងឺមហារីក ឬការព្យាបាលជំងឺមហារីកដោយកាំរស្មីឬដោយឱសថ។

ប្រសិនបើអ្នកមានជំងឺស្រាលតិចតួច ដូចជាផ្ដាសាយ អ្នកអាចទទួលថ្នាំបង្ការបាន។ ប្រសិនបើអ្នកឈឺ កំរិតមធ្យមឬធ្ងន់ធ្ងរ អ្នកប្រហែលជាគួរតែរង់ចាំរហូតដល់អ្នកបានជាសះស្បើយមុនពេលទទួលកំរិតថ្នាំ បង្ការតាមធម្មតាជាប្រចាំ(មិនទាន់ត្រូវរងប៉ះពាល់នឹងវីរុស) នៃថ្នាំបង្ការជំងឺឆ្កែឆ្កួត។

**ប្រសិនបើអ្នកបានត្រូវរងប៉ះពាល់ជាមួយនឹងវីរុសជំងឺឆ្កែឆ្កួត អ្នកគួរតែទទួលថ្នាំបង្ការមិនថាឡើយអ្នកអាចនឹងមានជំងឺអ្វីមួយនោះឡើយ។**

## 5 តើអ្វីខ្លះជាគ្រោះថ្នាក់មកពីថ្នាំបង្ការជំងឺឆ្កែឆ្កួត?

ថ្នាំបង្ការ ដូចជាឱសថគ្រប់យ៉ាងទូទៅដែរ គឺអាចនឹងបង្កបញ្ហាធ្ងន់ធ្ងរបាន ដូចជាប្រតិកម្មអាលែកហ្ស៊ីធ្ងន់ធ្ងរជាដើម។ គ្រោះថ្នាក់នៃថ្នាំបង្ការបង្កនូវទុក្ខទោសធ្ងន់ធ្ងរ ឬសេចក្ដីស្លាប់ គឺមានតិចតួចជាខ្លាំង។

បញ្ហាធ្ងន់ធ្ងរមកពីថ្នាំបង្ការជំងឺឆ្កែឆ្កួតគឺកំរមានខ្លាំងណាស់។

**បញ្ហាកំរិតស្រាល**

- ការឈឺចាប់ ការឡើងក្រហម ការហើម ឬរមាស់នៅត្រង់កន្លែងចាក់ (30%-74%)
- ឈឺក្បាល ចង្អោរ ឈឺពោះ ឈឺសាច់ដុំ វិលមុខ (5%-40%)

**បញ្ហាកំរិតមធ្យម**

- ឡើងហើមកន្ទួលពោលស្បែក ឈឺចាប់នៅត្រង់សន្លាក់ គ្រុនក្ដៅ (ប្រហែល 6% នៃការផ្ដល់ថ្នាំ បង្ការកំរិតរំលឹក)

វិបត្តិខុសប្រក្រតីដទៃទៀតនៅលើប្រព័ន្ធប្រសាទ ដូចជាប្រជុំរោគសញ្ញា Guillain-Barré (GBS) ត្រូវបានរាយការណ៍មកដែរក្រោយទទួលថ្នាំបង្ការជំងឺឆ្កែឆ្កួតរួចមក ប៉ុន្ដែប្រការនេះកើតមានយ៉ាងកំររហូត ដល់ថ្នាក់គេមិនដឹងថាតើវាមានទាក់ទងទៅនឹងថ្នាំបង្ការឬក៏អត់ទេ។

កំណត់សំគាល់៖

មានម៉ាកយីហោជាច្រើននៃថ្នាំបង្ការជំងឺឆ្កែឆ្កួតនៅក្នុងសហរដ្ឋអាមេរិក ហើយប្រតិកម្ម អាចនឹងប្រែប្រួលខុសៗគ្នារវាងម៉ាកយីហោទាំងឡាយ។ អ្នកផ្ដល់សេវាកម្មដល់អ្នកអាចផ្ដល់នូវព័ត៌មានបន្ថែមអំពីម៉ាកយីហោជាក់លាក់ណាមួយ។

## 6 ចុះបើមានប្រតិកម្មធ្ងន់ធ្ងរវិញ?

**តើខ្ញុំគួរស្វែងរកអ្វី?**

- ស្វែងរកនូវអ្វីដែលធ្វើឲ្យអ្នកមានការបារម្ភ ដូចជាសញ្ញានៃប្រតិកម្មអាលែកហ្ស៊ីធ្ងន់ធ្ងរ គ្រុនក្ដៅខ្ពស់យ៉ាងខ្លាំង ឬបំលាស់ប្ដូរអាកប្បកិរិយា។
  សញ្ញានៃប្រតិកម្មអាលែកហ្ស៊ីធ្ងន់ធ្ងរអាចរួមមានការឡើងហើមកន្ទួលលើស្បែក ការហើមត្រង់មុខ និងបំពង់ក លំបាកដកដង្ហើម ចង្វាក់ដង្ហើមញាប់ វិលមុខ និងខ្សោយ។
  រោគសញ្ញាទាំងនេះនឹងចាប់ផ្ដើមចេញតែប៉ុន្មាននាទីរហូតដល់ប៉ុន្មានម៉ោងបន្ទាប់ពីការផ្ដល់ថ្នាំបង្ការ។

**តើខ្ញុំគួរធ្វើអ្វីខ្លះ?**

- ប្រសិនបើអ្នកគិតថាវាជាប្រតិកម្មអាលែកហ្ស៊ីធ្ងន់ធ្ងរឬស្ថានភាពបន្ទាន់ដទៃទៀតដែលអ្នកមិន អាចពន្យារពេលរង់ចាំបាន សូមទូរស័ព្ទទៅកាន់លេខ 9-1-1 ឬយកមនុស្សនោះទៅកាន់មន្ទីរពេទ្យនៅជិតបំផុត។ មិនដូច្នោះទេ សូមទូរស័ព្ទរកវេជ្ជបណ្ឌិតរបស់អ្នក។
- បន្ទាប់មក ប្រតិកម្មនោះគួរតែរាយការណ៍ជូនទៅ "ប្រព័ន្ធរាយការណ៍ពីហេតុភេទមិនល្អរបស់ ថ្នាំបង្ការ" (VAERS)។ វេជ្ជបណ្ឌិតអ្នកអាចនឹងរក្សាទុកជាឯកសារនូវរបាយការណ៍នេះ ឬអ្នកអាច ធ្វើវាដោយខ្លួនឯងតាមរយៈគេហទំព័រ VAERS: **www.vaers.hhs.gov** ឬដោយទូរស័ព្ទទៅកាន់ លេខ **1-800-822-7967**។

*VAERS គឺសំរាប់តែរាយការណ៍ពីប្រតិកម្មប៉ុណ្ណោះ។ គេមិនផ្ដល់នូវដំបូន្មានផ្នែកវេជ្ជសាស្ត្រឡើយ។*

## 7 តើខ្ញុំស្វែងយល់បន្ថែមយ៉ាងដូចម្ដេច?

- សាកសួរវេជ្ជបណ្ឌិតរបស់អ្នក។
- ទូរស័ព្ទទៅកាន់នាយកដ្ឋានសុខាភិបាលក្នុងតំបន់ឬប្រចាំរដ្ឋអ្នក។
- ទាក់ទងទៅកាន់មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺ (CDC)៖
  - ចូលទៅកាន់គេហទំព័រជំងឺឆ្កែឆ្កួតរបស់ CDC នៅ **www.cdc.gov/rabies/**

---

Vaccine Information Statement

# Rabies Vaccine

Khmer

10/6/2009

Office Use Only

Translation provided by the California Department of Public Health